កោះសន្តិភាព
ថ្ងៃ សុក្រ ទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៦

# បារាំងស្លាប់នៅឆ្នេរសមុទ្រសង្ស័យចោរប្លន់

**ក្រុងព្រះសីហនុ :** សាកសពជនបរទេសម្នាក់ជាជនជាតិបារាំងត្រូវបានគេប្រទះឃើញដេកស្លាប់នៅពេលព្រឹកថ្ងៃទី១៣ ខែកញ្ញា ត្រង់ចំណុចឆ្នេរសមុទ្រអូរឈើទាល មុខអតីតក្រុមហ៊ុនអារីស្តុន ក្នុងសង្កាត់លេខ៤ ខណ្ឌមិត្តភាព ដោយមានស្នាមរបួសជាប់ខ្លួន និងត្រូវបានសង្ស័យថា ជនបរទេសរូបនេះប្រហែលជាស្លាប់ដោយអំពើប្លន់សម្លាប់ ។

ប៉ូលិសក្រុងព្រះសីហនុដែលទៅពិនិត្យសាកសពឱ្យដឹងថា ជនបរទេសរូបនេះមានឈ្មោះ BLOUTN JEAN ជនជាតិបារាំង មានអាយុ៦៣ឆ្នាំ ភេទប្រុស បានចូលមកក្រុងព្រះសីហនុ កាលពីថ្ងៃទី៩ កញ្ញា ឆ្នាំ ២០០៦ ដោយស្នាក់នៅក្នុងសណ្ឋាគារខ្សាច់មាស និងកាន់លិខិតឆ្លងដែនលេខ OSAP ០៣៩៦០ ។ ចំពោះការស្លាប់នេះ ប៉ូលិសសន្និដ្ឋានជាជំហានដំបូងថា អាចបណ្តាលមកពីអំពើប្លន់បង្កឡើងដោយជនល្មើសណាមួយក្នុងពេលដែលជនរងគ្រោះធ្វើដំណើរកំសាន្តតាមឆ្នេរសមុទ្រពេលយប់ ព្រោះនៅលើខ្លួនសាកសព ប៉ូលិសពិនិត្យឃើញមានស្នាមរបួសមុខកាំបិតត្រូវគេចាក់មួយកាំបិតចំគល់. កខាងឆ្វេងមានឈាមហូរ និងនៅក្បែរកន្លែងកើតហេតុ ឃើញមានសំភារៈជ្រុះរាយប៉ាយ និងឃើញស្នាមប្រវាយប្រតប់គ្នាផងដែរ ។

ទោះជាយ៉ាងណាក្តី ប៉ូលិសជំនាញកំពុងបន្តស៊ើបអង្កេតរកមូលហេតុពិតប្រាកដនៃមរណភាពនេះហើយ ។ បើតាមការអះអាងពីអ្នកគ្រប់គ្រងសណ្ឋាគារខ្សាច់មាសឱ្យដឹងថា ជនរងគ្រោះស្នាក់នៅបន្ទប់លេខ៣៣៤ ជាន់ទី៣ ក្នុងសណ្ឋាគារខ្សាច់មាស ហើយនៅយប់កើតហេតុ ជនរងគ្រោះបានធ្វើដំណើរចេញពីសណ្ឋាគារ ក្នុងដំណើរទេសចរណ៍ដូចសព្វដង ក៏ស្រាប់តែបាត់មិនឃើញត្រឡប់មកបន្ទប់ស្នាក់នៅវិញទេ រហូតដល់ព្រឹកឡើងទើបឮថា ជនបរទេសរូបនេះ ដេកស្លាប់នៅឯឆ្នេរសមុទ្របាត់ទៅហើយ ក្រៅពីនេះខាងសណ្ឋាគារគ្មានព័ត៌មានអ្វីផ្សេងទៀតទេ។

បច្ចុប្បន្នសាកសពជនជាតិបារាំងរូបនេះសមត្ថកិច្ចបានសហការបញ្ជូនទៅស្ថានទូតបារាំង ដើម្បីចាត់ចែងតាមនីតិវិធី ៕

**តារារា**